# ព្រះរាជក្រឹត្យ

នស/រកត/០១១៨/ ០៦៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឲ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៥ នាថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការបោះឆ្នោតជ្រើសតាំងរចនាសម្ព័ន្ធថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាព រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា។

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំងឯកឧត្តម លោកជំទាវ ជាទីប្រឹក្សាឯកឧត្តម **ឃុ ហុកគ្រី** អនុប្រធានទី១ ក្នុងនីតិកាលទី៥ នៃរដ្ឋសភា:

| | |
|---|---|
| ១- ឯកឧត្តម **អ៊ុន សុគន្ធ** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ២- ឯកឧត្តម **ពេជ្រ សុជេដ្ឋា** | មានឋានៈស្មើ រដ្ឋមន្ត្រី |
| ៣- ឯកឧត្តម **ឱ ប៊ុនី** | មានឋានៈស្មើ រដ្ឋលេខាធិការ និងជានាយកខុទ្ទកាល័យ បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៤- លោកជំទាវ **សារ៉េ ម៉ូរី** | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៥- ឯកឧត្តម **សំ សុវណ្ណារ៉ា** | មានឋានៈស្មើ រដ្ឋលេខាធិការ |
| ៦- ឯកឧត្តម **ប៊ុន រ៉ាដូ** | មានឋានៈស្មើ អនុរដ្ឋលេខាធិការ និងជានាយករងខុទ្ទកាល័យ បន្ថែមលើមុខងារបច្ចុប្បន្ន |
| ៧- ឯកឧត្តម **គង់ ប៊ុនណាត** | មានឋានៈស្មើ អនុរដ្ឋលេខាធិការ |
| ៨- ឯកឧត្តម **ឈន់ សុផាត** | មានឋានៈស្មើ អគ្គនាយក |
| ៩- ឯកឧត្តម **ទូច វណ្ណៈ** | មានឋានៈស្មើ អគ្គនាយក |
| ១០- ឯកឧត្តម **អៀ មេង** | មានឋានៈស្មើ អគ្គនាយក |

**មាត្រា២** : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត ព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៧.១៨០១.០៦៤

*ធ្វើនៅព្រះបរមរាជវាំង,ថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៨*

លេខ: ១១០ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៨

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**